# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Dec-22, 16:00
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សេចក្ដីសង្កេតមុនការផ្ទេរទីឃុំឃាំងលោកខៀវសំផន ក្រោយពីការថ្លែងសម្អាងហេតុពេញលេញនៅក្នុងសាលដីកានៃសំណុំរឿង ០០២/០២

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

ក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Fergal GAYNOR

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានចេញសេចក្តីថ្លែងការណ៍ពេញលេញអំពីសម្អាងហេតុនៃសាលក្រមនៅក្នុងសំណុំរឿង 00២/0២ ("សាលដីកា") ដែលនៅក្នុងនោះ តុលាការកំពូលបានអះអាងបញ្ជាក់ភាគច្រើនទៅលើការផ្តន្ទាទោសលោកខៀវ សំផន តាមរយៈសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។[1]

២. នៅក្នុងកថាខណ្ឌចុងក្រោយនៃសម្អាងសេចក្តីរបស់ខ្លួន តុលាការកំពូលបានបញ្ជាក់ម្តងទៀតថា « បង្គាប់ថា ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញលេញ និងការបញ្ចប់នូវការរៀបចំសម្រាប់ការផ្ទេរដោយអនុលោមតាមច្បាប់ទៅពន្ធនាគារដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់»។[2]

៣. មេធាវីការពារក្តី នៅក្នុងសំណើរបស់ខ្លួនចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ បានចោទជាសំណួរជាមូលដ្ឋានមួយចំនួនទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនលោក ខៀវ សំផន នាពេលអនាគត ដោយមើលឃើញពីវ័យច្រើន និងស្ថានភាពសុខភាពរបស់លោក។[3] នៅក្នុងសំណោរចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ សហព្រះរាជអាជ្ញាបានផ្តល់ព័ត៌មានមួយចំនួនអំពីស្ថានភាពនៃការចរចាជាមួយរដ្ឋាភិបាលកម្ពុជា។[4] ដោយយល់ព្រមទទួលស្គាល់ជាមួយនឹងក្រុមមេធាវីការពារក្តីស្តីពីភារកិច្ចនៃរដ្ឋាភិបាល

---

[1] សេចក្តីសង្ខេបនៃសាលដីកានេះ ប្រកាសក្នុងសវនាការនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ។ សេចក្តីថ្លែងការណ៍ទាំងស្រុងអំពីសម្អាងហេតុនៃសាលក្រម៖ សាលដីកាសម្រេចបន្ទាប់ពីសវនាការនៅក្នុងសំណុំរឿងលេខ 00២/0២ ដែលបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ឯកសារ **E465**។

[2] សាលដីកាសម្រេចបន្ទាប់ពីសវនាការ ក្នុងសំណុំរឿងលេខ 00២/0២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ , **F76**, ផ្នែកសម្រេចសេចក្តី ទំព័រ១២១៩។

[3] សំណើសុំទទួលបានពត៌មានពីសហព្រះរាជអាជ្ញា អំពីលក្ខខណ្ឌនៃការឃុំខ្លួនលោក ខៀវ សំផន ក្រោយពីមានការចេញសាលដីកាមានសំអាងហេតុពេញលេញលើសំណុំរឿង 00២/0២ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ឯកសារ **F77**។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន សុំពត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការឃុំឃាំង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ឯកសារ **F77/1**។

ក្នុងការធានាបាននូវលក្ខខណ្ឌនៃការឃុំខ្លួន ស្របតាមស្តង់ដារអន្តរជាតិ សហព្រះរាជអាជ្ញាបាន បង្ហាញពីកង្វះការគ្រប់គ្រងរបស់ពួកគេលើលក្ខខណ្ឌនៃការឃុំខ្លួននាពេលអនាគត ដែលជាការទទួលខុសត្រូវរបស់រដ្ឋបាលកម្ពុជា។ ក៏ប៉ុន្តែ ព័ត៌មានទាក់ទងនឹងអលទ្ធភាពនៃប្រព័ន្ធពន្ធនាគារកម្ពុជា ក្នុងការផ្តល់ការព្យាបាលវេជ្ជសាស្ត្រដល់លោក ខៀវ សំផន ដោយគ្មានជំនួយពីខាងក្រៅនោះ គឺពិតជាគួរឱ្យព្រួយបារម្ភខ្លាំងណាស់។[5]

៤. មេធាវីការពារក្តីបានទាក់ទងទៅក្រុមគ្រួសារលោកខៀវ សំផន ដែលចាត់មនុស្សពីរនាក់ទំនងជាអាចជួយដល់លោក ខៀវ សំផន បាន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះ និងក្នុងករណីដែលមិនមានផ្តល់យន្តការក្រោយចេញសាលដីកា មេធាវីការពារក្តីមើលឃើញមានការខ្វះចន្លោះផ្លូវច្បាប់ ពាក់ព័ន្ធនឹងរបៀបដំណើរការបន្ត ដើម្បីបំពេញអាណត្តិរបស់ខ្លួន និងជួយលោក ខៀវ សំផន ក្នុងបរិបទនៃការផ្ទេរកន្លែងឃុំខ្លួនលោក។ ដូច្នេះហើយ មេធាវីការពារក្តីមិនដឹងថាត្រូវងាកទៅរកខាងណា ដើម្បីទទួលបានការធានាលើការថែទាំសុខភាពរបស់លោក ខៀវ សំផន មុននឹងការផ្ទេរកន្លែងជូនលោកនោះឡើយ ហើយដើម្បីឱ្យមានការធានាថាមនុស្សដែលកំណត់អត្តសញ្ញាណដោយគ្រួសាររបស់លោក អាចផ្តល់ជំនួយប្រចាំថ្ងៃដល់លោក ទៅតាមតម្រូវការនៃអាយុ និង ស្ថានភាពសុខភាពរបស់លោក។

៥. ឥឡូវនេះ សាលដីកាត្រូវបានចេញជាលាយលក្ខណ៍អក្សរហើយ មេធាវីការពារក្តីស្នើសុំការបំភ្លឺឡើងវិញពីសំណាក់ពីអង្គជំនុំជម្រះតុលាការកំពូល ស្តីពីវិធីដំណើរការបន្ត ដោយបង្ហាញថា ខ្លួនគាំទ្រសំណើ ធ្វើឡើងដោយសហព្រះរាជអាជ្ញា ដែលតុលាការកំពូលបង្កើតឱ្យមានការត្រួតពិនិត្យជាផ្លូវការ ឬដំណើរការផ្ទេរការទទួលខុសត្រូវរបស់ អ.វ.ត.ក ដូចមានចែងក្នុងឧបសម្ព័ន្ធបន្ថែមនៃកិច្ចព្រមព្រៀងស្តីពីមុខងារដែលនៅសល់របស់ អ.វ.ត.ក។។[6]

---

[5] សូមមើលឯកសារ **F77/1** កថាខណ្ឌ ១០។

[6] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ខែសីហា ឆ្នាំ២០២១ ("កិច្ចព្រមព្រៀងបន្ថែម"). មាត្រា ២-១ (មុខងារសេសសល់)។

៦. មេធាវីការពារក្តីសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះនៃតុលាការកំពូលដែលបានយកការសង្កេតទាំងនេះមកពិចារណាក្នុងបរិបទនៃជំហានដែលត្រូវតែគិតគូរពីស្ថានភាពដែលមិនធ្លាប់មានពីមុនមក ដែលលោក ខៀវ សំផន ត្រូវប្រឈមមុខ ក៏ដូចជាមេធាវីការពារក្តី និងភាគីទាំងអស់ ក្នុងលក្ខខណ្ឌដែលមិនមានការបង្កើតឡើងយន្តការក្រោយការចេញសាលដីកា។

ធ្វើនៅទីក្រុងប៉ារីស និងទីក្រុងភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២

| | | |
|---|---|---|
| មេធាវី **គង់ សំអុន** | ទីក្រុងភ្នំពេញ | |
| មេធាវី **Anta GUISSÉ** | ទីក្រុងប៉ារីស | |